# និយាមប្រតិបត្តិ

## នីតិវិធីចុះបញ្ជីផ្តល់ និងប្រើប្រាស់

## បណ្ណមូលនិធិសមធម៌សុខាភិបាល (បណ្ណ ម.ស.ស.) ដល់ប្រជាជនគង្វះដែលជាបុគ្គលបម្រើការ ក្នុងសេវាកម្មរាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

វេជ្ជ. រស់ សីលវ៉ាត់

អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥

សន្និបាត ប្រចាំឆ្នាំ២០២៥

# មាតិកា

1. ការគាំពារសង្គមក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍
2. ប្រកាសរាជរដ្ឋាភិបាល លេខ០២ ប្រកព៖ ការផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍
3. ប្រកាសអន្តរក្រសួងលេខ ៣៥៩ សហវ.ប្រកអកគ៖ របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍
4. និយាមប្រតិបត្តិស្តីពីនីតិវិធីចុះបញ្ជីផ្តល់ និងប្រើប្រាស់បណ្ណមូលនិធិសមធម៌សុខាភិបាល ដល់ប្រជាជនគន្លឹះដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ ទាំងស្ត្រី បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទ
5. គោលដៅ

# កម្មវិធីគាំពារសង្គមក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

១. អ្នកផ្ទុកមេរោគអេដស៍ (PLHA)

- ឃុំ/សង្កាត់៖ យន្តការសម្ភាសផ្តល់បណ្ណសមធម៌
- មន្ទីរពេទ្យផ្តល់ថ្នាំប្រឆាំងមេរោគអេដស៍ (ART sites)៖ បណ្ណ មសស

២. ប្រជាជនគន្លឹះ (KPs)

- ឃុំ/សង្កាត់៖ យន្តការសម្ភាសផ្តល់បណ្ណសមធម៌
- គណៈកម្មាធិការអេដស៍ក្រុង/ស្រុក/ខណ្ឌ ៖ បណ្ណ មសស

# ប្រកាសរាជរដ្ឋាភិបាលលេខ ០២ ប្រកព

ចេញពីប្រកាស លេខ០២ ប្រកព រាជរដ្ឋាភិបាលសម្រេចផ្តល់ជម្រើស២ ៖

1. បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ក្រីក្រ អាចចុះឈ្មោះសុំសម្ភាសន៍ដើម្បីទទួលបាន**បណ្ណសមធម៌** តាមប្រកាសក្រសួងផែនការលេខ ០១១៩ ផក

2. បុគ្គលក្រៅពីនោះនឹងត្រូវចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល (**បណ្ណ ម.ស.ស.**) តាមប្រកាសអន្តរក្រសួងលេខ ៣៥៩ សហវ. ប្រកអកគ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០២ ប្រកព

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល**
**សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

ក្នុងបរិការណ៍នៃសុខសន្តិភាព និងស្ថេរភាពនយោបាយ, រាជរដ្ឋាភិបាលតែងតែគិតគូរយ៉ាងមធ្យ័តអំពីសុខុមាលភាពរបស់ប្រជាជនកម្ពុជាគ្រប់រូប ដោយឈរលើគោលនយោបាយ "មិនបោះបង់ពលរដ្ឋណាម្នាក់" ឡើយ។ ជាមួយនឹងការគិតគូរនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវអន្តរាគមន៍គាំពារសង្គមនានា ក្នុងគោលបំណងធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូល កាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំដៅកាត់បន្ថយ និងទប់ស្កាត់ការធ្លាក់ចុះក្នុងភាពក្រីក្រជាអតិបរមា ជូនប្រជាជនគ្រប់រូប។

ពេលនេះ រាជរដ្ឋាភិបាលសម្រេចផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសស្ត្រីដែលបម្រើការនៅតាមរង្គសាល, ឌីស្កូតេក, ខារ៉ាអូខេ, ហ្សែរ៉ាកេឌន, កន្លែងម៉ាស្សា និងស្ប៉ា ស្របតាមលេខតំបន់ទស្សនា គតិយុត្តជាធរមាន ដែលរដ្ឋនឹងរ៉ាប់រងនូវចំណាយទាំងស្រុង។

ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវរៀបចំបញ្ជីឈ្មោះបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ដើម្បីបញ្ជូនទៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ ដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ មុននឹងស្នើទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដើម្បីចុះបញ្ជីឱ្យពួកគាត់អាចទៅទទួលយកអត្ថប្រយោជន៍ក្រោមកញ្ចប់មូលនិធិសមធម៌សុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ នៅទូទាំងប្រទេស ដោយឥតបង់ថ្លៃ។

ថ្ងៃចន្ទ ៥រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២៣

# ប្រកាសអន្តរក្រសួង លេខ ៣៥៩ សហវ.ប្រក អកគ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥៩ សហវ.ប្រក អកគ

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់បុគ្គលបម្រើការ**
**ក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

**ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងសុខាភិបាល** | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកត/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.កប ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៩១ អ.នក្រ.បក ចុះថ្ងៃ២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- យោងតាមភាពចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**ជំពូកទី ១**
**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១.-**

ប្រកាសនេះកំណត់ពីយន្តការ និងនីតិវិធីគ្រប់គ្រងការផ្តល់តាវកាលិក និងការអនុវត្តរបបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**ប្រការ ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសស្ត្រី។

**ប្រការ ៣.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម÷

- បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ សំដៅដល់កម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសស្ត្រី ដែលបម្រើការនៅតាមរង្គសាល ឌីស្កូតែក ខារ៉ាអូខេ បៀរហោឌិន, កន្លែងម៉ាស្សា និងស្ប៉ា។

# ប្រកាសអន្តរក្រសួង លេខ ៣៥៩ សហវ.ប្រក អកគ

- មូលនិធិសមធម៌សុខាភិបាល សំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គមដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋជាក្រុមគោលដៅមួយចំនួនទទួលបាន ឬប្រើប្រាស់សេវាថែទាំសុខភាព ដោយឥតបង់ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈ ដែលរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស។

## ជំពូកទី ២
## ការចុះបញ្ជី

**ប្រការ ៤.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវរៀបចំបញ្ជីឈ្មោះបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ហើយត្រូវបញ្ជូនទៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ សម្រាប់ផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ មុននឹងស្នើទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដើម្បីចុះបញ្ជី។

**ប្រការ ៥-**

បុគ្គលបម្រើការងារដែលមិនស្ថិតក្រោមកិច្ចសន្យាការងារក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានសិទ្ធិដាក់ពាក្យស្នើសុំបណ្ណមូលនិធិសមធម៌សុខាភិបាលដោយផ្ទាល់ទៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ សម្រាប់ផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ មុននឹងស្នើទៅ ប.ស.ស. ដើម្បីចុះបញ្ជី។

**ប្រការ ៦-**

រដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ មានតួនាទីពិនិត្យ និងផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃបញ្ជីឈ្មោះរបស់បុគ្គលបម្រើការក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**ប្រការ ៧.-**

ប.ស.ស. ទទួលបន្ទុកចុះបញ្ជី និងចេញបណ្ណមូលនិធិសមធម៌សុខាភិបាល (បណ្ណ ម.ស.ស.)ដល់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ជំពូកទី ៣
## អត្ថប្រយោជន៍

**ប្រការ ៨.-**

របបថែទាំសុខភាពសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធមានអត្ថប្រយោជន៍ដូចមានកំណត់ក្នុងកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល។



**ប្រការ ៩.-**

កញ្ចប់សេវាព្យាបាល ការគ្រោងថវិកា និងនីតិវិធីអនុវត្តចំណាយក្នុងប្រកាសនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសអន្តរក្រសួងលេខ៤៩៧ សហវ/ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨។

**ប្រការ ១០.-**

បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវប្រើប្រាស់សេវាសុខាភិបាលតាមប្រព័ន្ធផ្តល់សេវាពីថ្នាក់បឋមនៅមូលដ្ឋានសុខាភិបាលថ្នាក់ទាបទៅមូលដ្ឋានសុខាភិបាលថ្នាក់ខ្ពស់ជាង។ ក្នុងករណីសង្គ្រោះបន្ទាន់, ជនរងគ្រោះ ឬអ្នកជំងឺអាចទៅទទួលសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតបំផុត។

## ជំពូកទី ៤
## ប្រភពហិរញ្ញប្បទាន

**ប្រការ ១១.-**

រាល់ការចំណាយលើការផ្តល់សេវាថែទាំសុខភាពសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលត្រូវហិរញ្ញប្បទានដោយថវិការដ្ឋ។

## ជំពូកទី ៥
## សុពលភាពបណ្ណ

**ប្រការ ១២.-**

បណ្ណ ម.ស.ស. មានសុពលភាពរយៈពេល១ (មួយ) ឆ្នាំ។

## ជំពូកទី ៦
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ ១៣.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គមមានតួនាទីដឹកនាំការតាមដាន ត្រួតពិនិត្យប្រសិទ្ធភាព និងការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តមូលនិធិសមធម៌សុខាភិបាល។

**ប្រការ ១៤.-**

ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម មានសិទ្ធិចាត់តាំងមន្ត្រីជំនាញពាក់ព័ន្ធចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែង អំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះ។



## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ១៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន បេឡាជាតិសន្តិសុខសង្គម អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ២០២៣

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# នីតិវិធីចុះបញ្ជីផ្តល់ និងប្រើប្រាស់បណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស.) ដល់ប្រជាជនគន្លឹះ ដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទាំងស្ត្រី បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទ

1. និតិវិធីចុះបញ្ជីផ្តល់បណ្ណម.ស.ស.
   - ✓ការចាប់ផ្តើមសកម្មភាព
   - ✓ដំណើរការចុះបញ្ជីផ្តល់បណ្ណម.ស.ស.
2. និតិវិធីនៃការប្រើប្រាស់បណ្ណម.ស.ស.
3. អ្នកពាក់ព័ន្ធ និងតួនាទី

# ដំណើរការចុះបញ្ជីផ្តល់បណ្ណ ម.ស.ស. ដល់ប្រជាជនគន្លឹះ



# ការចាប់ផ្តើមសកម្មភាព

## គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ត្រូវ៖

- ✓ រៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន
- ✓ រៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ជាមួយមន្ទីរទេសចរណ៍ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សាខាបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ អង្គការសង្គមស៊ីវិល បណ្តាញបុគ្គលបម្រើការក្នុងសេវាកម្សាន្តដូចជា DFONPAM KHANA/RHAC MHSS/MHC/CWPD ដើម្បី៖
  - ➢ ជម្រុញភាពជាម្ចាស់លើការឆ្លើយតបនឹងមេរោគអេដស៍ ឆ្ពោះទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ ក្នុងមូលដ្ឋានរាជធានី ខេត្ត (ស្របតាមគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍)
  - ➢ ជម្រុញការយល់ដឹងពីគោលនយោបាយគាំពារសង្គមសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្ត នីតិវិធីចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល (បណ្ណម.ស.ស.) នីតិវិធីប្រើប្រាស់បណ្ណ និងកញ្ចប់អត្ថប្រយោជន៍
  - ➢ សហការរួមគ្នារៀបចំដំណើរការចុះបញ្ជីផ្តល់បណ្ណម.ស.ស. ដល់ប្រជាជនគន្លឹះដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្ត ទាំងស្ត្រី (EW) បុរសរួមភេទជាមួយបុរស (MSM) និងអ្នកបំប្លែងភេទ (TG) បម្រើការតាមគ្រឹះស្ថានកម្សាន្ត និងតាមសួនសាធារណៈ
  - ➢ បញ្ជាក់និងបែងចែកតួនាទី ភារកិច្ចរបស់ភាគីពាក់ព័ន្ធដែលចូលរួមក្នុងគម្រោងនេះ
- ✓ រៀបចំវគ្គផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ៖ ប្រតិបត្តិករសេវាកម្មកម្សាន្ត ឬម្ចាស់គ្រឹះស្ថានកម្សាន្ត អាជ្ញាធរមូលដ្ឋាន។

# ដំណើរការចុះបញ្ជីផ្តល់បណ្ណ ម.ស.ស.

## គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ ៖

- ✓ ចាត់ចែងចងក្រងបញ្ជីឈ្មោះប្រជាជនគន្លឹះ (KPs) ដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្ត ទាំងស្ត្រី (EW) បុរសរួមភេទជាមួយបុរស (MSM) និងអ្នកបំប្លែងភេទ (TG) តាមគ្រឹះស្ថានកម្សាន្ត និងតាមសួនសាធារណៈ ដោយមានការគាំទ្រពីអង្គការសង្គមស៊ីវិល បណ្តាញបុគ្គលបម្រើការក្នុងសេវាកម្សាន្ត ដូចជា DFONPAM KHANA RHAC MHSS MHC CWPD
- ✓ ពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃបញ្ជីឈ្មោះ
- ✓ បញ្ជូនបញ្ជីឈ្មោះដែលផ្ទៀងផ្ទាត់ហើយ ទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដើម្បីបញ្ជូនទៅសាខាប.ស.ស. រាជធានី ខេត្ត
- ✓ តាមដានវឌ្ឍនភាពនៃការបោះពុម្ពបណ្ណម.ស.ស
- ✓ ទទួលយកបណ្ណម.ស.ស. និងរៀបចំចែកជូនបុគ្គលបម្រើការក្នុងសេវាកម្សាន្ត
- ✓ ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលបម្រើការក្នុងសេវាកម្សាន្ត ទាំងស្ត្រី បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទ មួយឆ្នាំម្តង ដើម្បីស្នើសុំបន្តសុពលភាពបណ្ណ។

# ដំណើរការការចុះបញ្ជីផ្តល់បណ្ណ ម.ស.ស.

## គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ៖

- ✓ បញ្ជូនបញ្ជីឈ្មោះបុគ្គលបម្រើការក្នុងសេវាកម្សាន្ត ដែលទទួលបានពីគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌទៅសាខាប.ស.ស. រាជធានី ខេត្ត
- ✓ ទទួលបណ្ណបោះពុម្ពហើយ ពីសាខាប.ស.ស. រាជធានី ខេត្ត បញ្ជូនទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ ដើម្បីចែកជូនបុគ្គលបម្រើការក្នុងសេវាកម្សាន្ត
- ✓ ធ្វើរបាយការណ៍ការចុះឈ្មោះផ្តល់បណ្ណម.ស.ស. និងការប្រើប្រាស់បណ្ណ មកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ *ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍តាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨ ជូនសម្តេចនាយករដ្ឋមន្ត្រី និងរាជរដ្ឋាភិបាល។*

# ដំណើរការចុះបញ្ជីផ្តល់បណ្ណ ម.ស.ស.

## សាខា ប.ស.ស. រាជធានី ខេត្ត ៖

- ✓ បោះពុម្ពផ្តល់បណ្ណម.ស.ស. ដល់បុគ្គលបម្រើការក្នុងសេវាកម្សាន្ត ទាំងស្ត្រី បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទ តាមបញ្ជីឈ្មោះទទួលបានពីគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត
- ✓ បញ្ជូនបណ្ណម.ស.ស.ដែលបោះពុម្ពហើយ ទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដើម្បីចាត់ចែងចែកជូនបុគ្គលបម្រើការក្នុងសេវាកម្សាន្ត។

# អ្នកពាក់ព័ន្ធ និងតួនាទី

- **បណ្ដាញ DFONPAM ៖**
  - ជាអ្នកភ្ជាប់/សម្របសម្រួលរវាងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍/លេខាធិការដ្ឋានអេដស៍/កម្មវិធីអេដស៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គការសង្គមស៊ីវិល ទាក់ទងនឹងការប្រើប្រាស់បណ្ណម.ស.ស. ជម្រុញធ្វើតេស្តរកមេរោគអេដស៍ និងទទួលសេវាសុខភាពផ្សេងទៀត
  - ផ្ដល់ព័ត៌មានត្រឡប់ជូនប្រជាជនគន្លឹះតាមរយៈប្រព័ន្ធតាមដានដោយសហគមន៍ (CLM) ឬប្រព័ន្ធ ផ្ដល់ព័ត៌មានត្រឡប់ (PSF)

- **អង្គការ KHANA/RHAC/CRS/AHF ៖**
  - លើកទឹកចិត្តប្រជាជនគន្លឹះឱ្យមកចុះឈ្មោះស្នើសុំបណ្ណម.ស.ស ចូលរួមធ្វើតេស្តរកមេរោគអេដស៍ និងប្រើប្រាស់សេវាសុខភាពផ្សេងទៀត
  - នៅពេលចែកបណ្ណម.ស.ស ជូនប្រជាជនគន្លឹះ ត្រូវ ៖
    - ផ្ដល់ប្រឹក្សាស្ដីពីសារសំខាន់នៃការធ្វើតេស្តរកមេរោគអេដស៍ សេវាបង្ការ **PrEP** ការណាត់ជួបគ្រូពេទ្យ (**ART Adherence**) និងការពិនិត្យព្យាបាលជំងឺកាមរោគ
    - ពន្យល់ពីអត្ថប្រយោជន៍ និងរបៀបរបបនៃការប្រើប្រាស់បណ្ណម.ស.ស. ដើម្បីទទួលបានសេវាសុខភាពផ្សេងៗ។

- **មន្ទីរពេទ្យ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ៖**
  - ពន្យល់/បញ្ជាក់ពីអត្ថប្រយោជន៍នៃបណ្ណម.ស.ស. និងបណ្ណសមធម៌ ដល់ប្រជាជនគន្លឹះ
  - អនុវត្តគោលការណ៍សេវាមេត្រី (**Friendly Services**) និងវិធីសាស្ត្រគិតផលប្រយោជន៍អ្នកទទួលផលជាធំ (**People-Centered**) ក្នុងការទំនាក់ទំនងផ្ដល់សេវា

# គោលដៅ

អនុលោមតាមសេចក្តីសម្រេចនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ឆ្នាំ២០២៥ នាខែមិថុនា ឆ្នាំ២០២៥៖

1. ចុះបញ្ជីផ្តល់បណ្ណម.ស.ស. ដល់ប្រជាជនគន្លឹះដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទាំងស្ត្រី បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទ ឱ្យបាន **៥0% នៅដំណាច់ឆ្នាំ២០២៥**។

# កិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ:.........✓............អ.ជ.ប.ជ.អ.

**សេចក្តីសម្រេចចិត្ត**
**នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥**
**ថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩**
**ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥**

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥បានដំណើរការរយៈពេលមួយព្រឹកពេញ នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥ នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល មានចំនួនសរុប១៨០រូប។

កិច្ចប្រជុំបានថ្លែងអំណរគុណ និងកោតសរសើរចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងបន្តចូលរួមយ៉ាងសកម្មក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥ បានដាក់ចេញនូវការសម្រេចចិត្ត ដូចតទៅ៖

១- គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍបន្តចូលរួមអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា។

២- ក្រុមការងារចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ត្រូវ៖

- ពិនិត្យរៀបចំកែសម្រួលយុទ្ធសាស្ត្រពហុវិស័យ ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ក្នុងស្ថានភាពនៃការធ្លាក់ចុះហិរញ្ញប្បទានពីខាងក្រៅ។
- ពង្រឹងយន្តការសម្របសម្រួលដែលមានស្រាប់ ដើម្បីកៀរគរធនធានពីដៃគូអភិវឌ្ឍសម្រាប់បំពេញបង្គ្រប់ថវិកាដែលបានកាត់ពីកញ្ចប់ថវិកាមូលនិធិសកលឆ្នាំ២០២៤-២០២៦។

៣- ដាក់ខេត្តកំពង់ស្ពឺ និងខេត្តតាកែវជាខេត្តពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។

៤- ក្រុមការងារផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍លើកទី៦ ទាំង៥ក្រុម បន្តដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ដើម្បីសម្រេចគោលដៅដែលបានកំណត់។

៥- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជំរុញការបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តសារាចរអន្តរក្រសួងលេខ០០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

៦- ក្រសួងអប់រំ យុវជន និងកីឡាបង្កើនការផ្សព្វផ្សាយអំពីរបៀបបង្ការការឆ្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ និងកាត់បន្ថយការមាក់ងាយរើសអើងចំពោះអ្នកជំងឺអេដស៍និងប្រជាជនគន្លឹះ ដល់បុគ្គលិកអប់រំ សិស្ស និស្សិត និងក្រុមកីឡាករ កីឡាការិនីឱ្យបានទូលំទូលាយ។

៧- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បន្តដំឡើងនូវស្នាដៃអប់រំរឿងឃ្លីខ្លីៗដើម្បីបញ្ជ្រាបសារស្តីពីការបង្ការ ការទប់ស្កាត់ និងការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ និងណែនាំដល់ផលិតករខារ៉ាអូខេ ឱ្យដាក់ខ្លឹមសារអប់រំស្តីពីការចម្លងមេរោគអេដស៍និងជំងឺអេដស៍ ដោយរត់អក្សរខាងក្រោមពេលចាក់បញ្ចាំង។

៨- ក្រសួងព័ត៌មានបន្តគាំទ្រនិងជំរុញការផ្សព្វផ្សាយសារអប់រំ រឿងអប់រំខ្លីៗ ផលិតមាតិកាអប់រំថ្មីៗ និងបង្កើតវេទិកាពិភាក្សាអំពីរបៀបបង្ការការឆ្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ ជាពិសេស ម=ម និងកាត់បន្ថយការមាក់ងាយរើសអើងចំពោះអ្នកជំងឺអេដស៍និងប្រជាជនគន្លឹះឱ្យបានញឹកញាប់និងជាប់ជាប្រចាំ។

៩- គ្រប់រដ្ឋបាលរាជធានី ខេត្តត្រូវគាំទ្ររៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានចប់សព្វគ្រប់១០០% នាដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៥។

១០- រដ្ឋបាលរាជធានី ខេត្តស្វែងរកការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធជំរុញគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណ ម.ស.ស. ដល់ប្រជាជនគន្លឹះ ដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ ទាំងស្ត្រី(EW) បុរសរួមភេទជាមួយបុរស (MSM) និងអ្នកបំប្លែងភេទ(TG)ឱ្យបានលើសពី៥០%នៅដំណាច់ឆ្នាំ២០២៥ និងសហការជាមួយអង្គការសង្គមស៊ីវិលនិងបណ្តាញជាដៃគូ ខិតខំផ្សព្វផ្សាយទាក់ទាញប្រជាជនគន្លឹះមកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគ និងប្រើប្រាស់សេវាបង្ការការឆ្លងមេរោគអេដស៍នានា។

១១- ក្រសួងសុខាភិបាលបន្តពង្រីកសេវាធ្វើតេស្តរកមេរោគអេដស៍ សេវាផ្តល់ឱសថPrEP( ឱសថបង្ការមុនពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ) និងPEP( ឱសថបង្ការក្រោយពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍) និងបង្កើនការរកបាន និងការប្រើប្រាស់ស្រោមអនាម័យឱ្យមានប្រសិទ្ធភាព និងជាប់លាប់ដល់ក្រុមគោលដៅ ព្រមទាំងពង្រឹងការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ពីមាតាទៅទារក។

១២- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ និងបញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ខេត្តព្រះសីហនុ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥

**ប្រធានអង្គប្រជុំ**
**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**

# សូមអរគុណ!

# តាវកាលិក₂

[តា-វៈ-កា-លិក]

ន. អត្ថប្រយោជន៍ក្នុងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដែលត្រូវជូនដល់សមាជិកនៃស្ថាប័នណាមួយ នៅពេលសាមីជនជួបប្រទះនូវហានិភ័យជាយថាហេតុ បណ្ដាលឱ្យបាត់បង់លទ្ធភាពបំពេញការងារ។

## ៣. ប័ណ្ណសមធម៌

ក. សម្រាប់គ្រួសារក្រីក្រកម្រិត១ និងកម្រិត២




**-ប័ណ្ណសមធម៌-**

**ចេញដោយ៖** ក្រសួងផែនការ

**អត្ថប្រយោជន៍៖** ប្រើសេវាថែទាំសុខភាពឥតគិតថ្លៃ នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ ទូទាំងប្រទេស និងអត្ថប្រយោជន៍មិនមែនវេជ្ជសាស្ត្រ (ឧបត្ថម្ភសោហ៊ុយធ្វើដំណើរ, ថ្លៃអាហារអ្នកជំងឺ និងវិភាគទានបុណ្យសព)។

**បន្ទុកចំណាយដោយ៖** រាជរដ្ឋាភិបាល




**មន្ទីរពេទ្យផ្តល់ថ្នាំប្រឆាំងមេរោគអេដស៍** ( ART sites ) **៖ បណ្ណ មសស**

# ប្រភេទប័ណ្ណសម្រាប់ប្រើប្រាស់សេវាថែទាំសុខភាពឥតគិតថ្លៃ

## ១. ប័ណ្ណសមាជិក ប.ស.ស.

ក. ប័ណ្ណសមាជិក ប.ស.ស. សម្រាប់កម្មករនិយោជិតក្នុងប្រព័ន្ធ



ខ. ប័ណ្ណសមាជិក ប.ស.ស. សម្រាប់មន្ត្រីរាជការ និងអតីតយុទ្ធជន



**«ប័ណ្ណសមាជិក ប.ស.ស.»**

**ចេញដោយ៖** បេឡាជាតិសន្តិសុខសង្គម

**អត្ថប្រយោជន៍៖** ប្រើសេវាផ្នែកថែទាំសុខភាពឥតគិតថ្លៃនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ និងឯកជន ទូទាំងប្រទេស ដែលជាដៃគូជាមួយ ប.ស.ស., ផ្នែកហានិភ័យការងារ, ផ្នែកប្រាក់សោធន, និងតាវកាលិកនានា។

**បន្ទុកចំណាយដោយ៖** បេឡាជាតិសន្តិសុខសង្គម

## ២. ប័ណ្ណមូលនិធិសមធម៌សុខាភិបាល

ក. សម្រាប់ ក្រុមប្រឹក្សាឃុំ-សង្កាត់-ស្រុក-ក្រុង-ខណ្ឌ-រាជធានី-ខេត្ត



ខ. សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ



**«ប័ណ្ណមូលនិធិសមធម៌សុខាភិបាល»**

**ចេញដោយ៖** បេឡាជាតិសន្តិសុខសង្គម

**អត្ថប្រយោជន៍៖** ប្រើប្រាស់សេវាផ្នែកថែទាំសុខភាពឥតគិតថ្លៃនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ ទូទាំងប្រទេស។

**បន្ទុកចំណាយដោយ៖** រាជរដ្ឋាភិបាល